# ទាចចៅស្នេរ

**បទកាកគតិ**

កំណាព្យខ្ញុំចារ សូមអស់ខេមរា ពិនិត្យអោយជាក់
តាក់តែងដោយត្រង់ មិនចង់លួចលាក់ បញ្ហាជ្រៅរាក់
ទាក់រឿងសង្គម ។

ខ្ញុំតាំងសច្ចះ លើកពោលតាមថ្នាក់ យកធមិជាធំ
មិនដៀលមិនត្មិះ មិនចេះសើចយំ មិនគិតប្រមុំ
ឈ្លានពានសិទ្ធិ ។

ជួបពិតថាពិត មិនក្លែងប្រឌិត មួយក្លាយជាពីរ
មានផ្ទៃមេឃា និងព្រះបឋវី ត្រៃរ័ត្នមណី
ជួយជាសាក្សី ។

កំណាព្យកាព្យឃ្លោង ខ្ញុំគ្មានគំរោង ចែងចារស្រដី
តែចិត្តរែងគិត ត្បិតជួបរឿងថ្មី នឹងនៅធ្វើហី
សែនស្តាយវេលា ។

បើជួនចំចិត្ត ប៉ះត្រូវចរិត គំនិតឬកពារ
ញាតិផងកុំប៉ង ចងកម្មវេរា ជួយកែជួយវៀរ
មារយាទអាស្រូវ ។

ខ្ញុំស្តីរឿងខ្មែរ មារយាទមិនប្រែ មិនមែនទូទៅ
ខ្មែរយើងច្រើនណាស់ ល្អល្អះពេកកូវ សល់ខ្លះដែលនៅ
ប្រជែងក្អេងឬក ។

សូមញាតិអ្នកអាន រស់សុខក្សេមក្សាន្ត ត្រជាក់ដូចទឹក
សិរីសួស្តី ទាំងថ្ងៃយប់ព្រឹក មានចិត្តរលឹក
ស្និទ្ធស្នេហ៍ខ្មែរយើង ។

Ca. ០៨ ឧសភា ២០០៦

ភិក្ខុ ស្វាត សាលឿម